**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ: ០២៣/១០ កប.ស.ជ.ណ**

# សេចក្តីអំពាវនាវ

កន្លងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសង្កេតឃើញថា នៅក្នុងម៉ោងផ្សាយពាណិជ្ជកម្មដែលទិញ ឬឧបត្ថម្ភដោយគ្រឹះស្ថានបណ្តុះបណ្តាលភាសាបរទេសដែលមានបង្រៀនភាសាកូរ៉េនោះ ពិធីករ-ពិធិការិនីនៃស្ថានីយ៍ទូរទស្សន៍ ជាពិសេសស្ថានីយ៍វិទ្យុខ្លះបានធ្វើអត្ថាធិប្បាយ ឬផ្តល់ព័ត៌មានឆ្លើយឆ្លងជាមួយប្រិយមិត្តអ្នកស្តាប់ដោយផ្អែកលើប្រភពព័ត៌មានមិនផ្លូវការ ស្តីពីនីតិវិធីជ្រើសរើស និងបញ្ជូនពលករទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ ។ ដើម្បីចៀសវាងការភ័ន្តច្រឡំណាមួយដែលអាចកើតមានឡើងដោយប្រិយមិត្តអ្នកស្តាប់ ជាពិសេសបងប្អូនដែលមានបំណងទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េនោះ គណៈកម្មាធិការ សូមអំពាវនាវដល់ពិធីករ-ពិធីការិនី ទាំងអស់សូមបញ្ឈប់ការធ្វើអត្ថាធិប្បាយដោយផ្អែកលើព័ត៌មានមិនផ្លូវការទាំងនោះជាបន្ទាន់ ។

យោងអនុស្សរណយោគយល់រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃសាធារណរដ្ឋកូរ៉េ មានតែគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតែមួយគត់ដែលជាអ្នកសម្របសម្រួលការងាររដ្ឋបាលជាមួយ អង្គភាពអភិវឌ្ឍធនធានមនុស្ស នៃ សាធារណរដ្ឋកូរ៉េ ក្នុងការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ ដូច្នេះមានតែព័ត៌មាន និង ឯកសារដែលចេញ ផ្សាយដោយគណៈកម្មាធិការបណ្តុះ បណ្តាល និងបញ្ជូនពលករទៅបរទេសនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ តែប៉ុណ្ណោះដែលជាប្រភពព័ត៌មានផ្លូវការ។ព័ត៌មានដែលមានប្រភពពីអង្គការនានា ឬគ្រឹះស្ថាន បណ្តុះបណ្តាល ភាសាបរទេស ដែលមានបង្រៀនភាសាកូរ៉េណាមួយក៏ដោយគឺជាព័ត៌មានមិនផ្លូវការដែលតម្រូវឱ្យម្ចាស់ប្រភព និងអ្នកអត្ថាធិប្បាយព័ត៌មានត្រូវ ទទួលខុសត្រូវដោយផ្ទាល់នូវផលវិបាកនានាដែលអាចកើតមានឡើងដោយ ការផ្សព្វផ្សាយនោះ។

អាស្រ័យន័យដូចបានអំពាវនាវខាងលើ សូមស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងបណ្តាញសារព័ត៌មានទាំងអស់ជ្រាប និងចូលរួមសហការជាមួយគណៈកម្មាធិការដើម្បីរួមចំណែកអប់រំ និងទប់ស្កាត់ការបោកប្រាស់ណាមួយដែលអាចកើតឡើងជាយថាហេតុ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកគណៈកម្មាធិការតាមរយៈទូរស័ព្ទ ០២៣-៦៥២ ៥៧៧៧ / ០១២-២១៤ ៧០១ / ០១១-៣៨៣ ៧៣៥ / ០១៥-៦០៧ ៧១៧ នៅរៀងរាល់ម៉ោងធ្វើការ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១០

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការ**

**បណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស**

**ពេជ សោភ័ន**

**ចម្លងជូន :**

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងព័ត៌មាន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីអនុវត្ត"
-ឯកសារកាលប្បវត្តិ